# ក

## មាតិកា

### I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២០-១០-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/១០០៣/៣០៤ ស្តីពីការតែងតាំងឯកឧត្តម ០២ រូប ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី ១ ជំនួសសមាជិកព្រឹទ្ធសភា ០២ រូប ដែលបានលាលែង ទៅបំពេញភារកិច្ចថ្មី ៣២៦៦


### II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២៤-១០-២០០៣ -អនុក្រឹត្យ លេខ ៨៨៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣២៦៧

២៨-១០-២០០៣ -អនុក្រឹត្យ លេខ ៨៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣២៦៨

២៩-១០-២០០៣ -អនុក្រឹត្យ លេខ ៨៩០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ៣២៦៩


### ២-សេចក្តីសំរេច


២៩-១០-២០០៣ -សេចក្តីសំរេច លេខ ៦៧ សសរ ស្តីពីការប្រគល់សិទ្ធិ ៣២៧០


### ៣-សារាចរ


២០-១០-២០០៣ -សារាចរ លេខ ០៣ សរ ស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៣២៧២


### III-ការិយាល័យក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍


២០-១០-២០០៣ -ប្រកាស លេខ ៣០៩ បទ.ប្រក ស្តីពីការបង្កើតគណៈកម្មការរៀបចំទីតាំងថ្មី នៃអាគារប្រៃសណីយ៍ និង ទូរគមនាគមន៍បារិត ៣២៧៧


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា


២១-១០-២០០៣ -ប្រកាស លេខ ៩៩៤ អយក.ប្រក ស្តីពីការបើកសាលាមធ្យមសិក្សាចំនេះទូទៅឯកជន " លិប ឃុន " ស្ថិតនៅក្នុងសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ៣២៧៩

២១-១០-២០០៣ -ប្រកាស លេខ ៩៩៥ អយក.ប្រក ស្តីពីការបើកសាលាមធ្យមសិក្សាចំនេះទូទៅឯកជន " ហួម អហ្វ អ៊ីងគ្លីស " ស្ថិតនៅក្នុងសង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានី ភ្នំពេញ ៣២៨១

២១-១០-២០០៣ -ប្រកាស លេខ ៩៩៦ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យឯកជន " អាត់វេនទីស្ទកម្ពុជា " ទៅជាវិទ្យាល័យឯកជន " អាយ ស៊ី ស៊ី កម្ពុជា " ស្ថិតនៅក្នុងឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ៣២៨៣

# ខ


| | | |
|---|---|---|
| ២១-១០-២០០៣ | -ប្រកាស លេខ ៩៩៧ អយក.ប្រក ស្តីពីការបើកសាលាចំនេះទូទៅឯកជន " វេស្ទើនអន្តរជាតិ " ស្ថិតនៅក្នុងសង្កាត់បឹងកក់ ១ ខណ្ឌទួលគោក រាជធានី ភ្នំពេញ | ៣២៨៤ |
| ២១-១០-២០០៣ | -ប្រកាស លេខ ៩៩៨ អយក.ប្រក ស្តីពីការបើកវិទ្យាល័យ តាកែវ ស្ថិតនៅក្នុងឃុំពាមមន្ទារ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | ៣២៨៦ |
| ២១-១០-២០០៣ | -ប្រកាស លេខ ៩៩៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ព្រែកឫស្សី-ល្វាឯម ស្ថិតនៅក្នុងព្រែកឫស្សី ស្រុកល្វាឯម ខេត្តកណ្តាល | ៣២៨៧ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ធិបតី ស្ថិតនៅក្នុងឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង | ៣២៨៨ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ សំឡូត ស្ថិតនៅក្នុងឃុំតាសាញ់ ស្រុកសំឡូត ខេត្តបាត់ដំបង | ៣២៨៩ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ បឹងព្រះ ស្ថិតនៅក្នុងឃុំកំពង់ក្រែង ស្រុកកំពត ខេត្តកំពត | ៣២៩០ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ កូនសត្វ ស្ថិតនៅក្នុងឃុំកូនសត្វ ស្រុកកំពត ខេត្តកំពត | ៣២៩១ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០៤ អយក.ប្រក ស្តីពីការបើកវិទ្យាល័យ ហ៊ុន សែន មណ្ឌលគីរី ស្ថិតនៅក្នុងឃុំ ស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី | ៣២៩២ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០៥ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ កំពតក្រុង ស្ថិតនៅក្នុងឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត | ៣២៩៣ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ សំបូរមាស ស្ថិតនៅក្នុងឃុំសំបូរមាស ស្រុកកំពង់ចាម ខេត្តកំពង់ចាម | ៣២៩៤ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន កោះញែក ស្ថិតនៅក្នុងឃុំ ស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគីរី | ៣២៩៥ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន កែវសីមា ស្ថិតនៅក្នុងឃុំ ស្រែខ្ទម ស្រុកកែវសីមា ខេត្តមណ្ឌលគីរី | ៣២៩៦ |
| ២១-១០-២០០៣ | -ប្រកាស លេខ ១០០៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ អង្គសាយ ស្ថិតនៅក្នុងឃុំទួលសាលា ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ | ៣២៩៧ |


## ៣. ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ


| | | |
|---|---|---|
| ២៨-១០-២០០៣ | - សេចក្តីសំរេច លេខ ១១៤៨ សសរ.ស្តីពីការបង្កើតគណៈកម្មការរៀបចំការងារចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅកម្ពុជា | ៣២៩៨ |

# ព្រះរាជក្រឹត្យ

នស/រកត/១០០៣/៣០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩៣ និង មាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់មាត្រា ១១៩ថ្មី និង ១៩៧ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម ០២រូប ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសសមាជិកព្រឹទ្ធសភា ០២រូប ដែលបានលាលែង ទៅបំពេញភារកិច្ចថ្មី ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ឆ្នាំ ប៊ុនស្រ៊ុន** ជំនួសស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ**

២- ឯកឧត្តម **ឡាយ ឈុនសារ៉េត** ជំនួសឯកឧត្តម **ឈឹម សៀកឡេង**

**មាត្រា ២** : ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

លេខ: ២៤៧ ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

**សុខ តាន់**

៣រល-០៣-១០-៣១៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០០៣

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៧៧. អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា១ :** តែងតាំងលោក **ឆាយ សុខន** បច្ចុប្បន្ន ប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តយូណាន ស៊ីឈួន និងហ្គីហ្ស៊ូ ដែលមាននិវេសនដ្ឋាន នៅក្រុងគុនមិញ ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១១៩...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធាន ជួយកសាងព្រះវិហារវត្ត*សុវណ្ណគិរីមាយ* ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

១-ឧបាសក **នន ខាត់** សប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ២២.៨០០ ដុល្លារ

២-ឧបាសិកា **ខាន់ សីមខេន** សប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៥.៣៦៥ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

125

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៩០ អនក្រ.បក

# អ នុ ក្រឹ ត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ជាកិត្តិយសបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិត្តិយសបច្ឆាមរណៈ ជូនចំពោះសពលោកវរសេនីយ៍ទោ **ម៉ិញ ជៅ** អត្តលេខ ០២៣២៥ ស្នងការរង និងជាប្រធានការិយាល័យកណ្តាលសន្តិសុខ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៩ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៦៧...សសរ**

## សេចក្ដីសំរេច

## ស្ដីពី

## ការប្រគល់សិទ្ធិ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្ដីពី ការបង្កើត ឧត្ដមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## សំ រេ ច

**ប្រការ ១.-** ត្រូវបានប្រគល់សិទ្ធិជូន ឯកឧត្ដម **ប្រាក់ សុខុន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល និងជា ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី ជា អ្នកសំរបសំរួលគំរោង ស្ដីពីការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលសាធារណៈ ជំនួសឯកឧត្ដម **ស៊ុំ ម៉ាន់និត** ដែលត្រូវទៅព្យាបាល សុខភាពរយៈពេលវែង នៅប្រទេសបារាំង ។

**ប្រការ ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សា អាជ្ញាធរជាតិ គ្រប់ក្រសួង-ស្ថាប័ន ត្រូវអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ តុលា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *កាលប្បវត្តិ-ឯកសារ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ០៧ . សរ

# សារាចរ
## ស្តីពី
## សន្តិសុខស្បៀង និង អាហារូបត្ថម្ភ
## នៅក្នុងព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានបន្តបេសកកម្មឥតងាករេក្នុងការស្តារ និង អភិវឌ្ឍន៍ប្រទេសកម្ពុជាលើគ្រប់វិស័យ ដោយឈរលើនយោបាយសង្គមប្រជាធិបតេយ្យសេរីពហុបក្ស ។ ឯកសារច្បាប់មូលដ្ឋាន និង ឯកសារសំខាន់ៗ ដទៃទៀតដែលជាទស្សនទានរបស់រាជរដ្ឋាភិបាល ដូចជាឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ច្បាប់ភូមិបាល ឯកសារផែនការសេដ្ឋកិច្ចសង្គមលើកទី២ ត្រូវបានរៀបចំ ហើយនិងបានអនុម័តដោយរដ្ឋសភា និង ព្រឹទ្ធសភា ជាបន្តបន្ទាប់ ដើម្បីយកទៅអនុវត្តនិងផ្សព្វផ្សាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ការរៀបចំឡើងនូវប្រព័ន្ធ គ្រប់គ្រងរដ្ឋបាលវិមជ្ឈការ នៅតាមឃុំ-សង្កាត់ចាប់ពីដើមឆ្នាំ២០០២មក គឺជាចំណែកមួយនៃការប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសជាតិដោយសមធម៌អោយបានគ្រប់តំបន់ទីប្រជុំជនក៏ដូចជានៅគ្រប់ តំបន់ដាច់ស្រយាល និងពង្រឹងលទ្ធិប្រជាធិបតេយ្យអោយបានកាន់តែរឹងមាំ ។

អង្គសិក្ខាសាលាជាតិលើកទី១ នៅខែមេសា ឆ្នាំ១៩៩៩ និង សន្និសីទស្តីពីតួនាទីនៃជំនួយស្បៀងអាហារនៅកម្ពុជា បានដាក់ចេញនូវអនុសាសន៍ល្អៗ សំរាប់ថ្នាក់ជាតិ ថ្នាក់សហគមន៍ និងសំរាប់ថ្នាក់គ្រួសារ ដែលជាយន្តការគន្លឹះក្នុងការកាត់បន្ថយកង្វះអាហារូបត្ថម្ភ និង អសន្តិសុខស្បៀង ជាពិសេសលើស្ត្រីនិងកុមារ ហើយដែលរាជរដ្ឋាភិបាលបានបញ្ចូលអោយទៅជាកម្មវិធីនយោបាយ សំរាប់ការកាត់បន្ថយភាពក្រីក្រ និង សំរាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិកម្ពុជា ដែលបច្ចុប្បន្ននេះគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធបាននិងកំពុងអនុវត្តនូវអនុសាសន៍ទាំងនោះ ដោយទទួលបាននូវលទ្ធផលគួរជាទីមោទនៈ ។

ដើម្បីដោះស្រាយបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជាអោយកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ សំដៅកាត់បន្ថយភាពក្រីក្រអោយខាងតែបាន រាជរដ្ឋាភិបាលសូមណែនាំដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុងទាំងអស់ដោយមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៏វិស័យកសិកម្ម និងជនបទ ជាអ្នកសំរបសំរួល ៖

I. បន្តអនុវត្តអនុសាសន៍ដែលមានចែងក្នុងសារាចរលេខ **០៥ សរ** ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា

II. ទទួលអនុវត្តអនុសាសន៍គន្លឹះទាំង៦ ដែលមានចែងក្នុងសេចក្តីសំរេចចិត្តនៃអង្គសិក្ខាសាលាជាតិលើកទី២ ស្តីពីសន្តិសុខស្បៀង និង អាហារូបត្ថម្ភនៅកម្ពុជា កាលពីថ្ងៃទី០៣-០៤ ខែមិថុនា ឆ្នាំ២០០៣ ដូចខាងក្រោម ៖

១. លើកកំពស់អភិបាលកិច្ចល្អ ក្នុងផ្នែកផលិតកម្ម និង ការបែងចែកស្បៀង ដោយផ្តោតការយកចិត្តទុកដាក់លើបណ្តាខេត្ត ស្រុក ឃុំ ដែលផលិតស្រូវបានលើសពីសេចក្តីត្រូវការដើម្បីទំនាក់ទំនងអោយបានសមស្រប និងទាន់ពេលវេលាក្នុងការលក់ចែកចាយទៅខេត្ត ស្រុក ឃុំ ដែលផលិតស្រូវមិនបានគ្រប់គ្រាន់។

២. សិក្សាស្វែងយល់ពីតំបន់រាំងស្ងួតជាប្រចាំ ហើយរៀបចំយន្តការនៅនឹងកន្លែងដោះស្រាយអោយបានសមស្រប និងមាននិរន្តរភាព ដោយផ្តោតជាសំខាន់លើការផ្តល់ និងចែកចាយពូជស្រូវ ការពង្រឹងការងារធារាសាស្ត្រ ម៉ាស៊ីនបូមទឹក ថ្នាំសំលាប់សត្វចង្រៃ និងការផ្តល់សំភារៈកសិកម្មដទៃទៀតដល់ប្រជាជន ។

៣. រៀបចំយន្តការជំរុញការដាំបន្លែនិងដំណាំច្រើនមុខ ការចិញ្ចឹមសត្វតាមគ្រួសារអោយបានទូលំទូលាយ ដូចជា ការចិញ្ចឹមសត្វពាហនៈ សំរាប់យកទៅភ្ជួររាស់ និងសំរាប់យកទៅលក់ដើម្បីយកកំរៃ និងប្រាក់ចំណូលបន្ថែម ។

៤. ប្រើប្រាស់ឯកសារផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជាដោយបំបែកអោយទៅជាគំរោងតូចៗ ដើម្បីដាក់ជូនដៃគូជាតិ និងអន្តរជាតិក្នុងការអនុវត្ត ។

៥. កែលំអប្រព័ន្ធអប់រំ និងលើកកំពស់ការយល់ដឹងនៅតាមតំបន់ជនបទអំពីសារៈសំខាន់នៃសន្តិសុខស្បៀង និង អាហារូបត្ថម្ភដែលពាក់ព័ន្ធដល់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាជនអោយដល់មូលដ្ឋាន ដោយ ប្រើប្រាស់ខ្សែរយៈនៃក្រុមប្រឹក្សាឃុំ-សង្កាត់ ។

៦. ទន្ទឹមនឹងការជំរុញការស្តារ និង ការសង់សំណង់ធារាសាស្ត្រខ្នាតធំៗត្រូវផ្តោតការយកចិត្តទុកដាក់លើនយោបាយទឹកខ្នាតតូចៗតាមគ្រប់រូបភាព ដើម្បីផ្តល់ជូនសហគមន៍ និង គ្រួសារអោយបានច្រើន ដោយសុំការគាំទ្រពីអង្គការជាតិ និង អន្តរជាតិនានា ជាពិសេសអង្គការកម្មវិធីស្បៀងអាហារពិភពលោក។

ក្នុងការអនុវត្តអនុសាសន៍គន្លឹះទាំង៦ខាងលើ បញ្ហាពាក់ព័ន្ធក្នុងវិស័យដូចខាងក្រោម ត្រូវ ៖

***បញ្ហាពាក់ព័ន្ធនឹងសុខភាព អាហារូបត្ថម្ភ និងការអប់រំ***

១. ពង្រឹង និងពង្រីកកម្មវិធីអនាម័យទូទៅ សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅតាមគ្រឹះស្ថានសិក្សា ។

២. បង្កើនការយល់ដឹងជាសាធារណៈស្តីអំពីផលប៉ះពាល់ជាអវិជ្ជមាននៃការប្រើប្រាស់គ្រឿងញៀន។

៣. បង្កើនចំណេះដឹងដល់ បុគ្គលិកសុខាភិបាល និង បុគ្គលិកធ្វើការតាមសហគមន៍ ស្តីពីការអនុវត្តការចិញ្ចឹមទារកនិងកុមារដោយទឹកដោះម្តាយ និងការផ្តល់អាហារបន្ថែម ដើម្បីអោយពួកគេធ្វើការអប់រំបន្តដល់ស្ត្រីជាម្តាយ និង អ្នកថែទាំកុមារ។

៤. ជំរុញការរៀបចំច្បាប់ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសំរាប់ចិញ្ចឹមទារក និងកុមារតូចៗ នៅប្រទេសកម្ពុជា ។

៥. កាត់បន្ថយជំងឺស្លេកស្លាំងដែលបណ្តាលមកពីកង្វះជាតិដែកតាមរយៈការផ្តល់បន្ថែមនូវគ្រាប់ថ្នាំជាតិដែក និងលុបបំបាត់ បញ្ហាកង្វះជីវជាតិ A តាមរយៈការផ្តល់បន្ថែមនូវគ្រាប់ថ្នាំជីវជាតិ A ។

៦. ជំរុញការអនុវត្តអនុក្រឹត្យស្តីពីការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ ដើម្បីបង្កើនផលិតកម្ម អំបិលអ៊ីយ៉ូដ និងដើម្បីអោយប្រជាពលរដ្ឋអាចប្រើប្រាស់អំបិលអ៊ីយ៉ូដបាននៅទូទាំងប្រទេស ។

៧. បង្កើនចំណេះដឹងស្តីពីសុខភាពបន្តពូជរបស់យុវវ័យ និង វិធានការបង្ការជំងឺអេដស៍ តាមរយៈកម្មវិធី *"មិត្តអប់រំមិត្ត"* ។

៨. បណ្តុះបណ្តាលគ្រូឧទ្ទេស គរុសិស្ស និងគរុនិស្សិតនៅគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ អំពីអនាម័យទូទៅ សុខភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្ស ។

៩. ពង្រឹងយន្តការសំរបសំរួល និង បច្ចេកទេសអប់រំសុខភាព សន្តិសុខស្បៀង និង អាហារូបត្ថម្ភ ដោយមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គការ ជាតិ និង អន្តរជាតិ នានា ។

***បញ្ហាទាក់ព័ន្ធនឹងធនធានទឹក***

១. កែលំអកិច្ចសហការ រវាងក្រសួងដែលពាក់ព័ន្ធ និងលើកស្ទួយការចូលរួមយ៉ាងសកម្មរបស់សហគមន៍នៅគ្រប់គំរោង និងគ្រប់ជាន់ថ្នាក់ទាំងអស់ ។

២. រៀបចំអោយមានគោលការណ៍ណែនាំផ្សព្វផ្សាយច្បាស់លាស់ និងសាមញ្ញ ដើម្បីអោយមានការចូលរួមពីប្រជាពលរដ្ឋក្នុងការអនុវត្តគំរោង ។

៣. ពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័ននៃភ្នាក់ងាររដ្ឋាភិបាល ក្នុងការអនុវត្តនូវរាល់យុទ្ធសាស្ត្រនាពេលបច្ចុប្បន្ន ។

៤. អនុវត្តនូវគោលការណ៍នានាដើម្បីជំរុញអោយមានការចូលរួមពីដៃគូឯកជន និង សាធារណៈ ក្នុងការគ្រប់គ្រង និង អភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ។

៥. ពង្រីកសក្តានុពលតំបន់ស្រោចស្រពអោយបានសមស្រប ។

៦. កែលំអអោយប្រសើរឡើងវិញ និង ពង្រីកការគ្រប់គ្រងទឹកជំនន់ ។

***បញ្ហាទាក់ព័ន្ធនឹងដីធ្លី***

១. បន្តអនុវត្តអនុសាសន៍លេខ៥ នៃសារាចរលេខ ០៥ ស.រ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ១៩៩៩ ដោយអនុលោមតាមមាត្រា៥៩ និងមាត្រា៦២ នៃច្បាប់ភូមិបាល ។

២. ពង្រឹងការអនុវត្តការផ្សព្វផ្សាយអោយបានទូលំទូលាយនូវច្បាប់ភូមិបាល និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ទាក់ទងនឹងដីធ្លី ។

៣. ពង្រឹង និងបន្តដំណើរការយន្តការដែលមានស្រាប់ ដើម្បីដោះស្រាយបញ្ហាទំនាស់ដីធ្លី ។

៤. បង្កើតយន្តការសម្បទានដីសង្គមកិច្ចនៅគ្រប់ថ្នាក់ដើម្បីធានាការបែងចែកដីប្រកបដោយប្រសិទ្ធភាព ។

៥. កសាង និងអនុវត្តគំរោងសាកល្បងសំរាប់កម្មវិធីសម្បទានដីសង្គមកិច្ច ។

៦. ធ្វើការសិក្សាបន្ថែមទៀតអំពីសក្តានុពលនៃផលប៉ះពាល់ពីសម្បទានដីសង្គមកិច្ច ។
៧. កំណត់អត្តសញ្ញាណ ចាត់ចំណាត់ថ្នាក់ ធ្វើផែនទី និងធ្វើសនិទានកម្មដីរដ្ឋ និងដីនៅទំនេរសំរាប់ចែកជូនដល់ប្រជាពលរដ្ឋ ដែលត្រូវការដីពិតប្រាកដ ។
៨. កែលំអនីតិវិធីនៃការផ្តល់ដីសម្បទានសង្គមកិច្ច ។
៩. រៀបចំពង្រីកការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ។
១០. លើកកំពស់អភិបាលកិច្ចល្អក្នុងការងារសម្បទានដីសង្គមកិច្ច នៅថ្នាក់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និង ឃុំ-សង្កាត់ ។

## បញ្ហាទាក់ទ័ន្ធនឹងកសិកម្ម និង បរិស្ថាន

១. បន្តធ្វើការស្រាវជ្រាវ និងបង្កើនសមត្ថភាពផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ។
២. ជំរុញការធ្វើប្រពលវប្បកម្ម ប្រព័ន្ធកសិកម្មចំរុះ និងពង្រីកកម្មវិធីពិសេសសំរាប់សន្តិសុខស្បៀង ទូទាំងប្រទេស ។
៣. បន្តរៀបចំបង្កើត និងពង្រឹងសមាគមនៅថ្នាក់សហគមន៍អភិវឌ្ឍន៍កសិកម្ម សហគមន៍នេសាទ និង សហគមន៍ព្រៃឈើ ។
៤. ជំរុញការគ្រប់គ្រង និងអភិរក្ស ធនធានធម្មជាតិអោយមានចីរភាព ។
៥. លើកកំពស់ប្រព័ន្ធទីផ្សារ ជំរុញការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម និងការកែច្នៃកសិផល ។
៦. លើកទឹកចិត្តអោយស្ត្រីចូលរួមយ៉ាងសកម្ម ក្នុងការធ្វើសេចក្តីសំរេចចិត្តលើសកម្មភាពកសិកម្ម ។
៧. បង្កើតយន្តការតាមដានគ្រោះធម្មជាតិដើម្បីមានវិធានការជាក់ស្តែង និងទាន់សភាពការណ៍ ។
៨. កែលំអការគ្រប់គ្រងសហគមន៍លើបញ្ហាសន្តិសុខស្បៀងតាមរយៈការបង្កើតធនាគារស្រូវ សូនបន្លែ និង សមាគម ដែលមានមូលដ្ឋាននៅតាមសហគមន៍នានា ។
៩. លើកកំពស់កិច្ចការពារបរិស្ថាននៅតាមតំបន់ជនបទ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព តាមរយៈការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍នានា ការគ្រប់គ្រងសត្វល្អិតចំរុះ វិធានការណ៍ចំរុះថែទាំដំណាំ និងទេសចរណ៍បរិស្ថាន ។

## បញ្ហាទាក់ទ័ន្ធនឹងការងារអភិវឌ្ឍន៍ជនបទ

១. ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធជនបទ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ដោយយកពលកម្មជាមូលដ្ឋាន ដើម្បីបង្កើតការងារដល់ប្រជាពលរដ្ឋ បង្កើនឱកាសរកប្រាក់ចំណូលនៅតាមជនបទ និងដើម្បីលើកកំពស់ដល់ប្រជាកសិករអោយមានលទ្ធភាពទទួលបានអាហារសំរាប់ទទួលទាន ក្នុងរយៈពេលខ្លី និង បំរើដល់ការអភិវឌ្ឍសហគមន៍ផង ។
២. ផ្តល់ថវិកាសំរាប់ការថែទាំ បង្កើត និងពង្រឹងរចនាសម្ព័ន្ធនិងយន្តការថែទាំហេដ្ឋារចនាសម្ព័ន្ធ មាន ផ្លូវជនបទ អណ្តូងទឹក ប្រព័ន្ធប្រឡាយ និង សមិទ្ធផលនានាក្នុងសហគមន៍ អោយដំណើរការប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព ។

៣. លើកកំពស់ការផ្គត់ផ្គង់ទឹកស្អាតនៅតាមតំបន់ជនបទ តាមរយៈបង្កើនការវិនិយោគអោយចំគោលដៅ និងតាមរយៈ ការពង្រឹងសមត្ថភាពលើការថែទាំ និងដំណើរការ ។

៤. រៀបចំនិងកែលំអប្រព័ន្ធឥណទានជនបទ នូវកិរិតអត្រាការប្រាក់សមស្របមួយដែលផ្តល់លទ្ធភាពដល់កសិករក្រីក្រ សមាគមកសិករ និង សហគ្រាសធុនតូច និងមធ្យម ដោយផ្តោតជាសំខាន់ ទៅលើស្ត្រី ។

៥. ពង្រឹងយន្តការសំរបសំរួល និងការងារសហការចំណោមក្រសួង-ស្ថាប័នពាក់ព័ន្ធ គ្រប់កំរិត ពីថ្នាក់ជាតិ រហូតដល់ថ្នាក់មូលដ្ឋាន និងផ្សារភ្ជាប់ជំនួយសង្គ្រោះ ជំនួយឧបត្ថម្ភ និង ការស្តារឡើងវិញ ពេលមានគ្រោះទឹកជំនន់ ទៅនឹងការអភិវឌ្ឍជនបទរយៈពេលវែង ។

៦. បន្តពង្រឹងសមត្ថភាពរបស់សហគមន៍មូលដ្ឋាន រួមមានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីគ្រប់គ្រង ចាត់ចែង អនុវត្ត ថែទាំការអភិវឌ្ឍសហគមន៍ ។

៧. ពង្រីក និងពង្រឹងការយល់ដឹងស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅថ្នាក់មូលដ្ឋាន ។

៨. ជួយបង្កលទ្ធភាពប្រើប្រាស់ថាមពលដែលអាចមាននៅតាមជនបទ ដែលមានតំលៃថោក មានសុវត្ថិ-ភាព និង បរិស្ថានល្អ ។

ទទួលបានសារាចរនេះ រាជរដ្ឋាភិបាលសូមអោយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ និងអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុងសហការចាត់ចែងផ្សព្វផ្សាយ និងអនុវត្តអោយទទួលបាននូវប្រសិទ្ធភាពខ្ពស់ក្នុងស្មារតីទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់ និងត្រូវរាយការណ៍អំពីលទ្ធផលដែលសំរេចបានតាមដំណាក់កាលនិមួយៗមករាជរដ្ឋាភិបាល តាមរយៈក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដែលជាសេនាធិការប្រមូលទិន្នន័យលទ្ធផលចងក្រងឯកសារជាមូលដ្ឋានសំរាប់វិភាគជូននាយករដ្ឋមន្ត្រី ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួងនិងស្ថាប័ននានា
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ៣០៩ បទ.ប្រក

ភ្នំពេញ, ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០០៣

# ប្រកាស

## ស្តីពីការ បង្កើតគណៈកម្មការរៀបចំទីតាំងថ្មី នៃអាគារប្រៃសណីយ៍ និងទូរគមនាគមន៍ខាវិត

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួលនិងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ / បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-យោងតាមការងារចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការមួយ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលមានមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **ឡុង ទាំងហាន** អនុរដ្ឋលេខាធិការ ប្រធាន

២-ឯកឧត្តម **ទូច ហេង** អគ្គនាយក ប.ទ អនុប្រធាន

| | | | |
|---|---|---|---|
| ៣-លោក | ញាណ ស្រស់ | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៤-លោក | កែវ ទុង្គរិន | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៥-លោក | ឆេត ម៉ុន្ថា | ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | ព្រាប សុវិទ្ធី | ប្រធាននាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ៧-លោក | លី សំអាន | ប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ | សមាជិក |
| ៨-លោក | ឡៅ សារឿន | អនុប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស | សមាជិក |
| ៩-លោក | គឹម ឈន | ប្រធានមន្ទីរ ប.ទ ខេត្តស្វាយរៀង | សមាជិក |
| ១០-លោក | លី កាយបុទ្ធិ | ប្រធានការិយាល័យសំណង់ | សមាជិក |
| ១១-លោក | អ៊ឹម ទុត្ថា | ប្រធានមជ្ឈមណ្ឌលបញ្ជូនស៊ីញ៉ាល់ | សមាជិក |
| ១២-លោក | តុល ញ៉ឹក់ | អនុប្រធានមជ្ឈមណ្ឌលបញ្ជូនស៊ីញ៉ាល់ | សមាជិក |

**ប្រការ២** : គណៈកម្មការនេះ មានភារៈកិច្ច សិក្សារកទីតាំងថ្មី សំរាប់សាងសង់អាគារ ប្រៃសណីយ៍ និង ទូរគមនាគមន៍ បាវិត ដោយរៀបចំបែបបទ លើកគំរោងថវិកា សំរាប់ចំណាយលើការ រុះរើ សំភារះបរិក្ខាបច្ចេកទេស ពីកន្លែងចាស់មកកន្លែងថ្មី និងការសាងសង់អាគារថ្មី ទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយមានលក្ខណៈសមស្រប សំរាប់ធ្វើអាជីវកម្ម សេវាកម្មលើវិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

**ប្រការ៣** : គណៈកម្មការនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ **ឯកឧត្តមប្រធាន** ។

**ប្រការ៤** : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋាន ប.ទ--អធិការដ្ឋាន-នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ-នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស-មន្ទីរ ប.ទ ខេត្តស្វាយរៀង និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍ តាមខ្លឹមសារ នៃ ប្រកាសនេះ ។

**ប្រការ៦** : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រដ្ឋមន្ត្រី

សូ-ឃុន

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
-សាលាខេត្តស្វាយរៀង
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៥ " ដើម្បីអនុវត្តន៍ "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

C:\New school\Private school2.doc

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ........[illegible]........អយក.ប្រក

# ប្រកាស

**ស្តីពីការបើកសាលាមធ្យមសិក្សាចំនេះទូទៅឯកជន « លិប យុន »**
**ស្ថិតនៅក្នុងសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ**

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការបើកសាលារៀនចំនេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់លោក ទី អៀង ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកសាលាមធ្យមសិក្សាចំនេះទូទៅឯកជន « លិប យុន » ស្ថិតនៅក្នុងសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** សាលារៀនឯកជន លិប យុន ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៣ :** លោក ទី អៀង ជានាយកសាលាត្រូវដឹកនាំ ចាត់តាំង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និង ផ្នែកបច្ចេកទេសព្រមទាំងទទួលខុសត្រូវក្នុងការ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ។
- ជ្រើសរើសសិស្សអោយចូលរៀន ។
- ធានាដំណើរបង្រៀន និងរៀនអោយបានល្អ ។
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- ធានាអោយមានសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញតាមកាលកំនត់ ។

**ប្រការ ៤ :** ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលារៀននេះអនុវត្តខុសពីគោលការណ៍អប់រំរបស់រដ្ឋ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងនាយកសាលារៀនសាមីមាន ភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ ២០០៣ [illegible]

អ៊ឹម សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពតិមាន"
- សាលាក្រុងភ្នំពេញ" ដើម្បីជាពតិមាន"
- ដូចប្រការ ៥
- កាលប្បវត្តិ-ឯកសារ នា.មចទ

C:\New school\Private school2.doc

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ...៥៥៤...អយក. ប្រក

# ប្រកាស

ស្តីពីការបើកសាលាមធ្យមសិក្សាចំនេះទូទៅឯកជន « ហ្វូម អហ្វ អ៊ីងគ្លីស »

ស្ថិតនៅក្នុងសង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការបើកសាលារៀនចំនេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់លោកស្រី កន លីណា ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៣
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១** : អនុញ្ញាតអោយបើកសាលាមធ្យមសិក្សាចំនេះទូទៅឯកជន « ហ្វូម អហ្វ អ៊ីងគ្លីស » ស្ថិតនៅក្នុងសង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២** : សាលារៀនឯកជន ហ្វូម អហ្វ អ៊ីងគ្លីស ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៣** : លោកស្រី កន លីណា ជានាយិកាសាលាត្រូវដឹកនាំ ចាត់តាំង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេសព្រមទាំងទទួលខុសត្រូវក្នុងការ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ។
- ជ្រើសរើសសិស្សអោយចូលរៀន ។
- ធានាដំណើរបង្រៀន និងរៀនអោយបានល្អ ។
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- ធានាអោយមានសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញតាមកាលកំនត់ ។

**ប្រការ ៤** : ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលារៀននេះអនុវត្តខុសពីគោលការណ៍អប់រំរបស់រដ្ឋ ។

**ប្រការ ៥** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងនាយកសាលារៀនសាមីមានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣

**ស.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

<u>កន្លែងទទួល</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពតិមាន"
- សាលាក្រុងភ្នំពេញ" ដើម្បីជាពតិមាន"
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ.....៩១៨......អយក.ប្រក

# ប្រកាស

ស្តីពីការប្តូរឈ្មោះវិទ្យាល័យឯកជន « អាត់វេនទីស្មកម្ពុជា » ទៅជាវិទ្យាល័យឯកជន «អាយ ស៊ី ស៊ី កម្ពុជា» ស្ថិតនៅក្នុងឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់នាយកអង្គការថែរក្សាកុមារអន្តរជាតិនៅកម្ពុជា ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៣ ដោយមាន យោបល់ឯកភាព ពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១** : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យឯកជន « អាត់វេនទីស្មកម្ពុជា » បច្ចុប្បន្ន ទៅជាវិទ្យាល័យឯកជន «អាយ ស៊ី ស៊ី កម្ពុជា » ស្ថិតនៅក្នុងឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកវិទ្យាល័យសាមីមានភារកិច្ច រៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៣
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
" ដើម្បីជ្រាបជាពតិមាន"
- សាលាខេត្តកំពង់ធំ" ដើម្បីជាពតិមាន"
- ដូចប្រការ ៣
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\Private school2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ...៤៤៧........អយក.ប្រក

# ប្រកាស

ស្តីពីការបើកសាលាចំនេះទូទៅឯកជន « **វេស្ទើនអន្តរជាតិ** »

ស្ថិតនៅក្នុងសង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការបើកសាលារៀនចំនេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់លោក តែ ឡូរិន ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកសាលាចំនេះទូទៅឯកជន « វេស្ទើនអន្តរជាតិ » ពីថ្នាក់ទី ១ ដល់ទី ១២ ស្ថិតនៅក្នុងសង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** សាលារៀនឯកជន វេស្ទើនអន្តរជាតិ ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៣ :** លោក តែ ឡូរិន ជានាយកសាលាត្រូវដឹកនាំ ចាត់តាំង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និង ផ្នែកបច្ចេកទេសព្រមទាំងទទួលខុសត្រូវក្នុងការ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគុណវុឌ្ឍិសមស្រប ។
- ជ្រើសរើសសិស្សអោយចូលរៀន ។
- ធានាដំណើរបង្រៀន និងរៀនអោយបានល្អ ។
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- ធានាអោយមានសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញតាមកាលកំនត់ ។

